# Before you Sign

## សិទ្ធិនៃអាណាព្យាបាលនិងការចូលមកនៅក្បែរកូន

សូមស្វាគមន៍ចូលទៅក្នុងការមុននឹងអ្នកចសូមស្វាគមន៍ចូលទៅក្នុងការមុននឹងអ្នកចុះហត្ថលេខាPodcast (ប្រព័ន្ធផ្សាយដំណឹងក្នុងអ៊ីនធឺណិត).
ប្រព័ន្ធផ្សាយដំណឹងតាមរយៈអ៊ីនធឺណិតនេះបានធ្វើឡើងដើម្បីជួយលោកអ្នកឱ្យបានយល់ប្រសើរជាងមុនអំពីច្បាប់និងសិទ្ធិរបស់ខ្លួននៅក្នុងរដ្ឋអង់តារីយ៉ូ។
ប្រសិនបើលោកអ្នកយល់ពីសិទ្ធិនិងការទទួលខុសត្រូវរបស់ខ្លួន លោកអ្នកនឹងអាចជ្រើសរើសនូវអ្វីៗដែលអ្នកដឹងថាល្អហើយត្រឹមត្រូវសម្រាប់ការរស់នៅរបស់លោកអ្នកនៅក្នុងប្រទេសកាណាដា។
សំខាន់ខ្លាំងណាស់លោកអ្នកត្រូវដឹងថាព័ត៏មានដែលផ្សាយចេញតាមប្រព័ន្ធអ៊ីនធឺណិតនេះគឺមិនមែនជាដំបូន្មានច្បាប់អជ្ញាដើម្បីជួយដោះស្រាយស្ថានការណ៍របស់លោកអ្នកនោះទេ។ ដំណឹងទាំងនេះគ្រាន់តែជាដំណឹងអំពីច្បាប់អជ្ញាខ្លះៗតែប៉ុណ្ណោះដែលជួយលោកអ្នកឲ្យបានយល់ខ្លះៗដែលលោកអ្នកកំពុងតែប្រឈមមុខនាពេលបច្ចុប្បន្ន។

ថ្ងៃនេះយើងនឹងពិពណ៌នារឿងសិទ្ធិនៃអាណាព្យាបាលនិងការចូលមកនៅក្បែរកូន។ បើលោកអ្នកមានការរស់នៅដោយឡែកពីគ្នាឬមានការលែងលះគ្នាដាច់ស្រេច ព្រមទាំងមានកូន ជាមួយគ្នា លោកអ្នកប្រហែលជាមានចម្ងល់អំពីរឿងអាណាព្យាបាលរបស់កូន តើផ្ទះអ្នកណាឬក៏អ្នកណាដែលត្រូវទទួលកូនឲ្យទៅរស់នៅជាមួយ។ សិទ្ធិនៃអាណាព្យាបាលរបស់កូនគឺជាសិទ្ធិពេញច្បាប់ក្នុងការសម្រេចចិត្តសំខាន់ៗ អំពី ការថែរក្សា អប់រំបណ្តុះបណ្តាលកូនៗ។ ឧទាហរណ៍ដូចជា សាលារៀន តើកូនយើងខ្ញុំត្រូវទៅសាលាមួយណា? តើសេចក្តីជំនឿមួយណាខាងផ្នែកសាសនាកូនខ្លួននឹងត្រូវប្រតិបត្តិតាម? នឹងការសម្រេចចិត្តផ្នែកការថែរក្សាសុខភាពរបស់កូន។ សិទ្ធិនៃអាណាព្យាបាលរបស់កូននោះ មិនមែនអំពីកូនរស់នៅជាមួយនរណាម្នាក់នោះទេ។
លោកអ្នកទាំងសងខាងត្រូវសម្រេចចិត្តថាកូនរស់នៅជាមួយខាងអ្នកឬក៏ម្ខាងទៀត បន្ទាប់ពីការរស់នៅដាច់ឡែកពីគ្នាឬការលែងលះគ្នាដាច់ស្រេចរបស់លោកអ្នក។ គេហដ្ឋានដែលកូនរស់នៅនឹងសិទ្ធិនៃអាណាព្យាបាលជារឿងពីខុសគ្នា។

ឧទាហរណ៍ បើលោកអ្នកមានសិទ្ធិជាអាណាព្យាបាលរបស់កូន នោះលោកអ្នក ជាអ្នកសម្រេចចិត្ត តែមួយគត់ សម្រាប់កូន កូនអាចរស់នៅជាមួយអ្នកណាម្នាក់ដោយចែកជាពេលវេលាទាំងសងខាងស្មើៗគ្នាក៏បាន។ ឬកូនរបស់លោកអ្នកអាចរស់នៅជាមួយនឹងលោកអ្នកណាម្នាក់តែមួយកន្លែងក៏បាន
ប៉ុន្តែលោកអ្នកអាចមានសិទ្ធិក្នុងការសម្រេចចិត្តអំពីរឿងសាលារៀនរឿងកាន់សាសនាហើយនឹងរឿងថែរក្សាសុខភាព។
សិទ្ធិជាអាណាព្យាបាលរួមគ្នាមិនមែនជាពេលវេលានៅក្បែរខ្លួនកូនច្រើនជាងអ្នកណាម្នាក់នោះឡើយ។

គេហដ្ឋានប្រចាំរបស់កូននោះហៅថាជាគេហដ្ឋានចម្បង។ គេហដ្ឋានចំបងមានន័យថាកូនរបស់លោកអ្នករស់នៅទីនោះច្រើនជាងកន្លែងផ្សេងទៀត ឬក៏រស់នៅទីនោះគ្រប់ពេលវេលា។
ប្រសិនបើលោកអ្នកជាអ្នកអាណាព្យាបាលតែមួយគត់នោះ គេហដ្ឋានរបស់លោកអ្នក តែងតែជាគេហដ្ឋានចំបងរបស់កូនដែរ
ចំណែកឯម្ខាងទៀតគ្រាន់តែមានសិទ្ធិអាចចូលមកចំណាយពេលវេលាជាមួយកូនតែប៉ុណ្ណោះ។

គេហដ្ឋានបែងសម្រាប់កូន នោះកូន រស់នៅក្នុងគេហដ្ឋានទាំងសងខាងស្មើៗគ្នា។ គេហដ្ឋានមួយចាត់ទុកជាគេហដ្ឋានចម្បង គេហដ្ឋានមួយទៀតជាគេហដ្ឋានបន្ទាប់។

ប្រសិនបើគូរបស់លោកអ្នកសម្រេចចិត្តថាកូននៅគេហដ្ឋានមួយណានោះលោកអ្នកដាក់ជាលាយលក្ខណ៍អក្សរ ចូលទៅក្នុងកិច្ចព្រមព្រៀង។

## Before you Sign

ប្រសិនបើជាលោកអ្នកនៅមានទំនាស់ លោកអ្នកអាចសុំជំនួយពីអ្នកជំនាញផ្នែកច្បាប់ អ្នកច្បាប់នេះហើយ ជាជំនួយផ្នែកច្បាប់អាជ្ញា ដើម្បីជួយដោះស្រាយតាមផ្លូវច្បាប់រហូតដល់អ្នកទាំងពីរព្រមព្រៀង។ លោកអ្នកអាចចូលទៅសាលាក្តី ដើម្បីសុំឲ្យចៅក្រមជាអ្នកសម្រេចចិត្តជួសលោកអ្នក។

លោកចៅក្រម នឹងយក ការពិសោធន៍មួយ ហៅថា "ចំណាប់អារម្មណ៍ល្អបំផុតសម្រាប់កូន"

ដើម្បីដោះស្រាយថាតើគេហដ្ឋានមួយណាដែលកូនរបស់លោកអ្នកនិងរស់នៅ។ លោកចៅក្រម តែងតែសន្និដ្ឋានថាជាការប្រសើរសម្រាប់កូនដើម្បីអោយកូនមានទំនាក់ទំនងជាមួយនឹងឪពុកនិងម្តាយ បន្ទាប់ពីទទួលការរស់នៅដាច់ដោយឡែកពីគ្នានិងការលែងលះគ្នាដាច់ស្រេច។

ចំណាប់អារម្មណ៍ល្អបំផុតសម្រាប់កូន តែងតែពិសោធន៍ ដោយពិចារណា ពីសិទ្ធិនៃអាណាព្យាបាល និងសិទ្ធិចូលជិតកូន ដូចជា

ទំនាក់ទំនងរវាងម្តាយនិងកូនឬឪពុកនិងកូន

អារម្មណ៍ដែលប្រទាក់គ្នារវាងម្តាយឬរវាងឪពុកជាមួយនឹងកូន

រយៈកាលដែលកូនបានរស់នៅក្នុងស្ថានការណ៍ដែលមានលំនឹង

គម្រោងការរបស់ប្តីឬប្រពន្ធអំពីការចិញ្ចឹមបីបាច់កូន

ក្នុងករណីខ្លះ លោកចៅក្រមពិចារណាពីគំនិតនិងបំណងរបស់ក្មេង ប្រសិនជាមានការធ្វើបាបកូនឬ ក៏មានការធ្វើបាបនៅក្នុងក្រុមគ្រួសារ ឬក៏កូនណាមួយផ្សេងទៀត ក្នុងស្ថានភាពភាគច្រើន កូនតែងបានទទួលភាពកក់ក្តៅដោយរស់នៅជាមួយឪពុកឬម្តាយទាំងសងខាង។ មិនមែន ជាការចំណាយពេលវេលា របស់កូននិងឪពុកឬម្តាយ ស្មើៗ គ្នានោះទេ ប៉ុន្តែ ទំនាក់ទំនងនេះត្រូវមានអត្ថន័យជាចំណងជាសាច់ជាឈាមរវាងកូននិងឪពុកឬនិងម្តាយ។

ប្រសិនបើជាមានប្រវត្តិធ្វើបាបក្មេងនិងអំពើហិង្សាផ្សេងៗនៅក្នុងគ្រួសាររឿងដែលគួរបារម្ភផ្សេងទៀត សាលាក្តី ប្រហែលជាដាក់អាជ្ញា គ្រប់គ្រង ឪពុកឬម្តាយ ក្នុងការចូលជិតកូន។

ពួកយើងសង្ឃឹមថាលោកអ្នក តាមរយៈផ្សាយដំណឹងតាមអ៊ីនធឺណិត បានរកឃើញ ប្រភពល្អមួយដែលផ្សាយប្រាប់ ច្បាប់អាជ្ញាអំពីសិទ្ធិនៃអាណាព្យាបាល និងសិទ្ធិចូលជិតកូន បន្ទាប់ពីទទួលការរស់នៅដាច់ដោយឡែកពីគ្នានិងការលែងលះគ្នាដាច់ស្រេច។ ប្រសិនបើជាលោកអ្នកមានសំណួរអំពីការរស់នៅដាច់ឡែកពីគ្នា នឹងការលែងលះគ្នា សូមលោកអ្នកស្តាប់បន្តនូវព័ត៏មានទាំងនេះតាមរយៈអ៊ីនធឺណិតដែលមានប្រធានបទអំពីរឿងរ៉ាវទាំងអស់នេះ។

ប្រសិនបើលោកអ្នកនៅមានសំណួរអំពីរពីរឿងទាំងអស់នេះ សូមមេត្តាគិតដើម្បីត្រឡប់មកសួរតាមតាមរយៈភ្នាក់ងារបម្រើសេវាកម្ម ហើយនិងអ្នកដែលប្រាប់លោកអ្នកអំពីព័ត៏មានតាមអ៊ីនធឺណិតនេះ។

បើសិនជាលោកអ្នកមានម៉ាស៊ីនគិតស្វ័យប្រវត្តិ(កុំព្យូទ័រ)អាចចូលទៅក្នុងទំព័រអ៊ីនធឺណិតឈ្មោះជំហានចូលទៅក្នុងយុត្តិធម៏ (stepstojustice.ca) ឬអង្គការអន្តោប្រវេសន៍(settlement.org)ដើម្បីទទួលព័ត៏មានបន្ថែម។ ប្រសិនបើជាលោកអ្នកបានដឹងថាខ្លួនត្រូវការដំបូន្មានដែលត្រឹមត្រូវតាមច្បាប់, ការគាំទ្រ, ឬអ្នកច្បាប់សម្រាប់ជាតំណាងរបស់លោកអ្នក, សូមទាក់ទងមកភ្នាក់ងារជំនួយផ្នែកច្បាប់រដ្ឋអង់តារីយ៉ោ(Legal Aid Ontario) ១-៨០០-៦៦៨-៨២៥៨ ពីថ្ងៃច័ន្ទទល់ថ្ងៃសុក្រ ពីម៉ោង 8ព្រឹកដល់ម៉ោង 5ល្ងាច (EST) ដែលមានជាភាសាផ្សេងៗគ្នាចំនួន 300 ភាសា។ ព័ត៏មានដែលចេញផ្សាយតាមប្រព័ន្ធអ៊ីនធឺណិតនេះបានទទួលឧបត្ថម្ភជាប្រាក់ដោយភ្នាក់ងារបម្រើឈ្មោះគ្រឹះស្ថានច្បាប់ (LAW FOUNDATION)(YWCA-ST THOMAS) សហគមន៍យុវតីគ្រីស្ទានទីក្រុងសាំងតូម៉ាស់ទទួលខុសត្រូវនៅក្នុងព័ត៏មាននេះដែលសរសេរជាលាយលក្ខណ៍អក្សរចេញផ្សាយ។